# ឯកសារជំនួយស្មារតី

# ស្តីពី

# ទំនាក់ទំនងប្រទេសកម្ពុជា-ប្រទេសជប៉ុន

# ៩-កុម្ភៈ-២០២០

## ១. អំពីប្រទេសជប៉ុន

ប្រទេសជប៉ុនគឺជាប្រទេសមួយដែលមានការរីកចម្រើនស្ទើរតែគ្រប់វិស័យហើយមានរចនាសម្ព័ន្ធក្នុងការគ្រប់គ្រងប្រជាជនបានយ៉ាងល្អទើបធ្វើឱ្យប្រទេសមានការអភិវឌ្ឍរហូតដល់សព្វថ្ងៃ។ ខាងក្រោមនេះគឺជាចំណេះដឹងទូទៅដែលទាក់ទងទៅនឹងប្រទេសជប៉ុន។ ប្រទេសជប៉ុនដែលត្រូវបានគេនិយាយភាសាជប៉ុនថា "នីប៉ូ" ឬ "នីហុន" គឺជាប្រទេសកោះប៉ាស៊ីហ្វិកមហាសមុទ្រនៅឆ្នេរសមុទ្រនៃអាស៊ីអាគ្នេយ៍។ កោះនេះមានទំហំប្រហែល 6.900 ។ កោះដែលល្បីល្បាញនិងមានប្រជាជនច្រើនបំផុតគឺកោះ Honshu, Hokkaido, Shikoku និង Kyushu ដែលមានចំនួន 97% នៃប្រទេស។ នៅក្នុងកោះទាំងនេះមាន ៤៧ ខេត្តដែលមានប្រជាជនសរុប ១២៧ លាននាក់ និងជាប់ចំណាត់ថ្នាក់ទី ១១នៅក្នុងពិភពលោក) ។ 73% នៃប្រទេសជប៉ុនគឺជាតំបន់ភ្នំ ទោះបីយ៉ាងណាក៏ដោយ ប្រជាជននៅនៅប្រទេសជប៉ុនរស់នៅតាមឆ្នេរសមុទ្រយ៉ាងច្រើនដែលធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសមួយដែលមានប្រជាជនច្រើនបំផុតនៅក្នុងពិភពលោក។[1]

## ១.១. ស្ថានភាពនយោបាយនិងសង្គម

កាលពីខែកក្កដា ឆ្នាំ២០១៩ នាយករដ្ឋមន្ត្រីជប៉ុនលោក អាបេ ស៊ីនហ្សូ បានប្រកាសពីជ័យជម្នះនៃគណបក្ស ចម្រុះរបស់លោកនៅក្នុងការបោះឆ្នោតសភាជាន់ខ្ពស់ ប៉ុន្តែមិនបានឈ្នះ សំឡេងភាគច្រើន ២ភាគ៣ ដើម្បីអាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ បែបសន្តិនិយមបាននោះឡើយ។ គណបក្សប្រជាធិបតេយ្យសេរីនិយម (LDP) របស់ លោក អាបេ នឹងគណបក្សជាដៃគូក្រុមចម្រុះ កូមេអ៊ីតុ (Komeito) ទទួលបានសំឡេងគាំទ្រ ១៤១ អាសនៈ ខណៈក្រុមគណបក្សប្រឆាំងទទួលបាន១០៤អសនៈ ក្នុងចំណោមអសនៈសរុប ២៤៥។ សំឡេង ១៦៤អសនៈ ឬ ២ភាគ៣ គឺជាសំឡេងចាំបាច់នៅក្នុងសភាទាំងពីរ របស់ជប៉ុនក្នុងការដាក់ឱ្យសំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្លាយទៅជាការធ្វើប្រជាមតិថ្នាក់ជាតិ។ តែទោះជាមិនបានទទួលបានសំឡេងភាគច្រើនដាច់ខាតនេះក៏ដោយ ក៏លោក អាបេ នៅតែអះអាងដដែលថា តាមរយៈជ័យជម្នះនេះបានបង្ហាញថា ប្រជាជនជប៉ុនចង់បានស្ថេរភាព

[1] *https://www.globalizationpartners.com/2017/12/11/japanese-culture-andtradition*

នយោបាយ ហើយវាក៏ផ្តល់ឱ្យលោកផងដែរនូវអំណាចគាំទ្រនយោបាយ និងរបៀបវារៈការទូតរបស់លោក។[2] លោក អាបេ ស៊ីនហ្សូ ធ្វើការរុះរើគណៈរដ្ឋមន្ត្រីទ្រង់ទ្រាយធំផងដែរ។[3]

បច្ចុប្បន្នក៏មានបញ្ហាដែលសម្រាប់ប្រជាជនជប៉ុន ខណៈដែលកំណើនប្រជាជនជុំវិញពិភពលោកបានកើនឡើងក្នុងល្បឿនមួយដែលគួរឱ្យព្រួយបារម្ភ គឺថារយះពេលប្រមាណទសវត្សរ៍ចុងក្រោយនេះ កំណើនប្រជាជនរបស់ជប៉ុនបែរជាមានការធ្លាក់ចុះវិញ។ ហេតុផលនោះគឺដោយសារតែប្រជាជនរបស់ខ្លួនមិនសូវមាននរណាចង់រៀបការ និងមានកូននោះទេ ដូច្នេះហើយធ្វើឱ្យចំនួនមនុស្សចាស់ច្រើនជាងចំនួនកូនក្មេង។ ជាការឆ្លើយតបទៅនឹងបញ្ហាមួយនេះ រដ្ឋាភិបាលជប៉ុន បានបង្កើតគោលនយោបាយមួយចំនួនដូចជា៖ ១. **ធ្វើឱ្យបរិយាកាសការងារមានភាពប្រសើរជាងមុន ៖** បរិយាកាសការងារមានការប្រកួតប្រជែង និងកិច្ចការច្រើន ដូច្នេះហើយធ្វើឱ្យបុគ្គលិកម្នាក់ៗមិនសូវមានពេលសម្រាប់គ្រួសារនោះទេ ។ **២. ពង្រឹងសេវាថែទាំក្មេង** ៖ ដោយសារតែគ្មានអ្នកមើលថែទាំកូនរបស់ពួកគេនៅពេលដែលគេទៅធ្វើការ។ **៣. លើកទឹកចិត្តចំណូលស្រុក ៖** ចំនួនប្រជាជនសកម្មរបស់ជប៉ុនមានចំនួនតិច បើប្រៀបធៀបទៅជាមួយនឹងតម្រូវការការងារ រដ្ឋាភិបាលជប៉ុនបានលើកទឹកចិត្តការចំណូលស្រុកពីជនបរទេសឱ្យមកបម្រើការងារនៅក្នុងប្រទេសខ្លួន។ ការណ៍នេះបានធ្វើឱ្យវិស័យមួយចំនួនដែលពុំមានបុគ្គលិកគ្រប់គ្រាន់អាចមានកម្លាំងគ្រប់គ្រាន់វិញ។ **៤. ផ្តល់ប្រាក់លើកទឹកចិត្ត ៖** ដើម្បីលើកទឹកចិត្តឱ្យប្តីប្រពន្ធចង់បង្កើតកូន រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ថវិកាសម្រាប់កូនម្នាក់ចំនួន ១៨០ ០០០ យ៉េន ដែលស្មើនឹង $១៦៨៤ ដុល្លារអាមេរិក។ ជាលទ្ធផលកំណើនប្រជាជនដែលកើននោះគឺឃើញកើតឡើងនៅតាមតំបន់មួយចំនួនប៉ុណ្ណោះ សម្រាប់ប្រទេសទាំងមូល បញ្ហាកំណើនប្រជាជនអវិជ្ជមាននៅតែរឿងគួរឱ្យព្រួយបារម្ភ។[4]

## ១.២. ស្ថានភាពសេដ្ឋកិច្ច

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ធនាគារកណ្តាលជប៉ុនបានដំឡើងការព្យាករពីកំណើនសេដ្ឋកិច្ចរបស់ខ្លួនសម្រាប់ប្រទេសមានសេដ្ឋកិច្ចធំជាងគេទី ៣ របស់ពិភពលោកនេះ ប៉ុន្តែបានរក្សាគោលនយោបាយបន្ធូរបន្ថយរូបិយវត្ថុខ្លាំងបំផុតរបស់ខ្លួនមិនផ្លាស់ប្តូរ។ ធនាគារនេះរំពឹងថានឹងមានសេដ្ឋកិច្ចនឹងកើនឡើង ០,៩ ភាគរយ នៅក្នុងឆ្នាំដែលបញ្ចប់នៅខែមីនាឆ្នាំ ២០២១ ដែលអត្រានេះត្រូវបានដំឡើងពីការព្យាករលើកមុនដែលថាមានកំណើន ០,៧ ភាគរយ។ ការវាយតម្លៃកាន់តែល្អប្រសើរនេះបានធ្វើឡើងបន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ស៊ីនហ្សូ អាបេ បានដាក់ចេញកញ្ចប់វិធានការជំរុញសេដ្ឋកិច្ច

---

[2] *Freshnewsasia ៖ ចុះផ្សាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ៖ "ទីបំផុតគណបក្សចំរុះរបស់លោក អាបេ ស៊ីនហ្សូ ទទួលជ័យជម្នះក្នុងការបោះឆ្នោតសភាជាន់ខ្ពស់ (Video inside)"។*

[3] *សង្គមនិងកីឡា ssn-news ៖ ចុះផ្សាយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ៖ "នាយករដ្ឋមន្ត្រីជប៉ុនលោក អាបេ ស៊ីនហ្សូ ធ្វើការរុះរើគណៈរដ្ឋមន្ត្រីទ្រង់ទ្រាយធំ"។*

[4] *Bizkhmer ៖ ចុះផ្សាយថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ៖ "គោលនយោបាយរបស់ជប៉ុន ក្នុងការដោះស្រាយបញ្ហាអវិជ្ជមាននៃកំណើនប្រជាជន"។*

មួយកាលពីឆ្នាំមុន ដើម្បីគាំទ្រសេដ្ឋកិច្ចនេះ និងកាត់បន្ថយផលប៉ះពាល់ដោយសារការបង្កើនពន្ធលើការប្រើប្រាស់កាលពីខែតុលាពីអត្រា ៨ ទៅ ១០ ភាគរយ។ ធនាគារកណ្តាលបានឲ្យដឹងថា៖ *«សេដ្ឋកិច្ចរបស់ជប៉ុនបានស្ថិតលើនិន្នាការកើនឡើងក្នុងកម្រិតមធ្យម ទោះបីជាការនាំចេញ ការផលិត និងទំនុកចិត្តធុរកិច្ចបានបង្ហាញភាពចុះខ្សោយមួយចំនួនក៏ដោយ ដែលភាគច្រើនបានរងផលប៉ះពាល់ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចក្រៅប្រទេស និងគ្រោះមហន្តរាយធម្មជាតិ»*។ ទោះបីយ៉ាងណាការបង្កើនពន្ធ និងគ្រោះមហន្តរាយធម្មជាតិកំពុងដាក់សម្ពាធទៅលើតម្រូវការក្នុងស្រុក។ ធនាគារនេះបានបន្តថា៖ *«ប៉ុន្តែតម្រូវការទំនងជានឹងមាននិន្នាការកើនឡើង»*។[5]

យោងតាមការចេញផ្សាយ ពីគេហទំព័រជប៉ុនធូដេនៅខែកុម្ភៈ ឆ្នាំ២០២០ ប្រទេសជប៉ុន បានកត់ត្រាឱនភាពពាណិជ្ជកម្មសម្រាប់ខែមករា ដោយសារការនាំចេញបានធ្លាក់ចុះ ចំពេលមានការព្រួយបារម្ភ អំពីការរីករាលដាលនៃវីរុសថ្មី ដែលអាចធ្វើឲ្យកំណើនសេដ្ឋកិច្ចក្នុងតំបន់បាត់បង់ជីវិត ក្រសួងហិរញ្ញវត្ថុជប៉ុន បាននិយាយនៅក្នុងរបាយការណ៍មួយថា ឱនភាពពាណិជ្ជកម្មសម្រាប់ខែមុន មានចំនួនសរុប ១,៣ ពាន់ពាន់លានយ៉េន។ នោះគឺជាឱនភាពពាណិជ្ជកម្ម រយៈពេល៣ខែជាប់ៗគ្នា សម្រាប់សេដ្ឋកិច្ចធំបំផុតទី៣ របស់ពិភពលោក។ កាលពីខែតុលា ឆ្នាំ២០១៩ ប្រទេសនេះបានគ្រប់គ្រងអតិរេកពាណិជ្ជកម្មមួយភាគធំ ដោយសារតែការធ្លាក់ចុះតម្លៃប្រេងឆៅ បានប៉ះប៉ូវការធ្លាក់ចុះ នៃការនាំចេញ។ ការនាំចេញ និងការនាំចូលរបស់ជប៉ុនទៅចិន បានធ្លាក់ចុះកាលពីខែមករា ឆ្នាំ២០២០ ចំណែកការនាំចេញ និងនាំចូលទៅអាមេរិក ក៏បានធ្លាក់ចុះក្នុងខែនេះដែរ។ ការផ្ទុះឡើងនៃ CODIV-19 បានបញ្ឈប់ផលិតកម្មរោងចក្រ និងការការព្រួយបារម្ភបន្ថែមទៅលើអ្វីដែលបានកំណត់មុន ដោយគោលនយោបាយពាណិជ្ជកម្ម របស់ប្រធានាធិបតីអាមេរិកលោក ដូណាល់ត្រាំ។

## ១.៣. សហរដ្ឋអាម៉េរិកនិងប្រទេសជប៉ុនក្នុងឆ្នាំ២០១៩

នៅចុងខែឧសភា ឆ្នាំ២០១៩ ប្រធានាធិបតីអាមេរិកលោកដូណាល់ ត្រាំបានធ្វើដំណើរទស្សនកិច្ចផ្លូវរដ្ឋរយៈពេល ៤ថ្ងៃក្នុងប្រទេសជប៉ុន។ ការធ្វើទស្សនកិច្ចនេះដោយសារ ៖ **ទី១** កងទ័ពអាម៉េរិកនៅទឹកដីជប៉ុន (នៅយ៉ូកូស៊ូកា) **ទី២** លោកត្រាំចង់ឃើញលោកអាបេចូលរួមកាត់បន្ថយភាពតានតឹងរវាងអាមេរិក និងអ៊ីរ៉ង់ (ឆ្នាំ២០១៩ អ៊ីរ៉ង់ និងជប៉ុនប្រារព្ធខួបគម្រប់ ៩០ឆ្នាំនៃទំនាក់ទំនងការទូត) **ទី៣** លោកត្រាំប្រើសម្តីទន់ភ្លន់ និងសម្របសម្រួលជាមួយកូរ៉េខាងជើង[6] **ទី៤** លោកត្រាំ ជាប្រមុខរដ្ឋបរទេសទីមួយ ដែលត្រូវទទួលជួបដោយព្រះចៅអធិរាជថ្មី ណារ៉ុហ៊ីតូ។ ព្រះអង្គទើបឡើងសោយរាជកាលពីថ្ងៃទី ១ឧសភា ២០១៩ ស្នងពីបិតា អាគីហ៊ីតូ ដែលបានដាក់រាជ្យ។ ប្រមុខដឹកនាំបរទេសទាំងឡាយផ្សេងទៀត នឹងត្រូវចូលធ្វើគារវកិច្ចអធិរាជថ្មី នៅខែតុលាឯណោះទេ តែលោកត្រាំ បានទទួលកិត្តិយសពិសេសមុនគេ ចូលជួបព្រះចៅអធិរាជ និងក្រុមគ្រួសាររាជវង្ស អមដោយពិធីទទួលទាន

---

*[5] ភ្នំពេញប៉ុស្តិ៍ ៖ ចុះផ្សាយថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ៖ "ធនាគារកណ្តាលជប៉ុន ដំឡើងការព្យាករអំពីកំណើនសេដ្ឋកិច្ចរបស់ជប៉ុន"។*
*[6] វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ៖ "មុននឹងចាកចេញពីទឹកដីជប៉ុន លោកត្រាំបញ្ជាក់ពីអានុភាពយោធាអាមេរិកដែលគ្មានគូប្រៀបនៅតំបន់ប៉ាស៊ីហ្វិក"។*

អាហារស្រមោលស។[7] **ទី៤ ពាណិជ្ជកម្ម** ពោលគឺជញ្ជីងពាណិជ្ជកម្មលម្អៀងខ្លាំងមកខាងជប៉ុន ជាពិសេសគឺដោយសារតែការនាំចូលរថយន្តតែម្តង។ ជាសរុបអាមេរិកមានឱនភាពពាណិជ្ជកម្មជាមួយជប៉ុនក្នុងកំរិត ៦៨ពាន់លានដុល្លារ។ សម្រាប់តែខែមេសាឆ្នាំ២០១៩មួយ គម្លាតឱនភាពកាន់រីកធំបន្ថែម៦៥០លាន ព្រោះទីផ្សាររថយន្តជប៉ុននៅអាមេរិកបានស្គាល់កំណើនដល់ទៅ៨,៣%។ លោកត្រាំ បានប្រកាសចាត់ទុកឧស្សាហកម្មរថយន្តបរទេសនេះ ថាជាការគំរាមកំហែងសន្តិសុខជាតិអាមេរិកនោះ។ ប៉ុន្តែខាងភាគីជប៉ុន បានបញ្ជាក់ជាស្រេចហើយដែរ ថាប្រឆាំងដាច់ខាតនូវរាល់គំនិតផ្តួចផ្តើមចង់កំរិតការនាំចេញ ដែលជាទង្វើរំលោភច្បាប់ពាណិជ្ជកម្មពិភពលោក។[8] គួររំលឹកផងដែរថា ជប៉ុន និងអាល្លឺម៉ង់ ត្រូវបានលោកដូណាល់ ត្រាំ ចង្អុរមុខដោយចំៗ។ លោកដូណាល់ ត្រាំ ធ្លាប់បាននិយាយថា៖ "*ប្រទេសអឺរ៉ុប តូចតែមាឌទេ តែរកស៊ីខ្សែលើដាក់អាមេរិក សាហាវជាងចិនទៅទៀត*"។ លោកបន្ថែមថា៖ "*គេនាំឡាន Mercedes ចូលដីអាមេរិកយ៉ាងច្រើន ដូចនាំនំកុកគី មកលក់អញ្ចឹង*"។[9]

លោកត្រាំមិនបាននិយាយឈ្មោះប្រទេសចិនតែគេក៏ដឹងថា លោកត្រាំចង់បញ្ជូនសារទៅឲ្យចិនរឿងសមុទ្រចិនខាងត្បូង និងកូរ៉េខាងជើង។ ចំណែកនៅសមុទ្រចិនខាងកើតក៏រដ្ឋាភិបាលចិនកំពុងបន្តប្រឈមមុខទល់នឹងប្រទេសជប៉ុន រួមទាំងកោះតៃវ៉ាន់។ តែក្រោមភ្នែកប្រមុះរបស់រដ្ឋបាលអាមេរិក សមុទ្រចិនខាងត្បូងក៏ដូចសមុទ្រចិនខាងកើតមិនមែនជាកម្មសិទ្ធិផ្តាច់មុខរបស់ប្រទេសណាមួយទេ តែជាដែនទឹកអន្តរជាតិដែលគ្រប់គ្នាមានសិទ្ធិធ្វើចរាចរចេញ ចូលដោយសេរី។[10]

## ២.ទំនាក់ទំនងកម្ពុជានិងប្រទេសជប៉ុន

### ២.១.ប្រវត្តិទំនាក់ទំនងកម្ពុជានិងប្រទេសជប៉ុន

ប្រទេសកម្ពុជា និងប្រទេសជប៉ុនបានបង្កើតទំនាក់ទំនងការទូតជាផ្លូវការនៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៥៣។ ទំនាក់ទំនងនេះត្រូវបានប្រសើរឡើងយ៉ាងខ្លាំងនៅពេលដែលព្រះបាទនរោត្តមសីហនុបានធ្វើដំណើរទស្សនកិច្ចជាផ្លូវការទៅកាន់ប្រទេសជប៉ុននៅឆ្នាំ១៩៥៥ ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពរវាងប្រទេសទាំងពីរនិងការយល់ព្រមរបស់ជប៉ុន នៃការទទួលស្គាល់ទាក់ទងនឹងសកម្មភាពនៃការបោះបង់សិទ្ធិទាមទារសំណងនៃសង្គ្រាមរបស់ ជប៉ុនមកកម្ពុជា។ នេះជាឥរិយាបទទាំងស្រុងនៃប្រទេសកម្ពុជាឆ្ពោះទៅរកប្រទេសជប៉ុនបន្ទាប់ពីសង្គ្រាមលោកលើកទី២ តាមរយៈការផ្តល់ជំនួយទ្វេភាគី ដូចជាការបោះបង់ចោលសិទ្ធិទាមទារសំណងបន្ទាប់ពីប្រទេសជប៉ុនបានចាញ់សង្គ្រាម ហើយកម្ពុជាថែមទាំងបានផ្តល់ស្បៀងប្រទេសជប៉ុនក្នុងខណៈពេលដែលជប៉ុនកំពុងតែជួបការលំបាក

---

*[7] វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩ ៖ "ទស្សនកិច្ចប្រកបដោយនិមិត្តរូបរបស់ប្រធានាធិបតីអាមេរិកនៅជប៉ុន"។*

*[8] វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩ ៖ "ទៅជប៉ុនភ្លាម លោកត្រាំ រំលើករឿងវិសមភាពពាណិជ្ជកម្មភ្លាម"។*

*[9] វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ ៖ "លោកត្រាំ ទុកពេល៦ខែ ឲ្យជប៉ុននិងអឺរ៉ុប ដើម្បីចរចា ពុំនោះទេនឹងដំឡើងពន្ធនាំចូលរថយន្ត"។*

*[10] វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ៖ "មុននឹងចាកចេញពីទឹកដីជប៉ុន លោកត្រាំបញ្ជាក់ពីអានុភាពយោធាអាមេរិកដែលគ្មានគូប្រៀបនៅតំបន់ប៉ាស៊ីហ្វិក"។*

ក្រោយពីចាញ់សង្គ្រាម ដែលវាគឺជាកត្តាជំរុញឱ្យមានកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ទំនាក់ទំនងទ្វេភាគីត្រូវបានបង្អាក់នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ បន្ទាប់ពីរបបខ្មែរក្រហមកាត់បន្ថយទំនាក់ទំនងការទូតជាមួយប្រទេសជប៉ុននៅឆ្នាំ១៩៧៥។ បន្ទាប់មកនៅឆ្នាំ១៩៧៩ ដែលជារដ្ឋាភិបាលថ្មីរបស់ប្រទេសកម្ពុជាដែលគេហៅថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ប៉ុន្តែប្រទេសជប៉ុន នឹងសហរដ្ឋអាម៉េរិកមិនមានទំនាក់ទំនងផ្លូវការជាមួយរដ្ឋាភិបាលនេះទេ។ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងការដោះស្រាយជម្លោះនៅក្នុងប្រទេសកម្ពុជា ដែលបានត្រួសត្រាយផ្លូវសម្រាប់ការធ្វើទំនាក់ទំនងការទូតជាផ្លូវការរវាងប្រទេសទាំងពីរ។ ប្រទេសជប៉ុនបានចាប់ផ្តើមឱ្យមានស្ថានទូតប្រចាំកម្ពុជានៅក្នុងឆ្នាំ១៩៩២ ខណៈពេលដែលប្រទេសកម្ពុជាបានបើកឡើងវិញនូវស្ថានទូតរបស់ខ្លួនប្រចាំប្រទេសជប៉ុននៅក្នុងឆ្នាំ១៩៩៤[11] ។

## ២.២.ទំនាក់ទំនងផ្នែកនយោបាយ

តាំងពីឆ្នាំ១៩៩២ រហូតមកទល់ឆ្នាំ២០១៣ ជាមធ្យម ជប៉ុនផ្តល់ជំនួយឱ្យកម្ពុជាប្រមាណ១០០លានដុល្លារក្នុងមួយឆ្នាំ ជាពិសេសដើម្បីជួសជុល ឬកសាងហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតធនធានមនុស្សនៅកម្ពុជា។ ជាផ្លូវការ រដ្ឋាភិបាលជប៉ុនបន្តបន្ទាប់គ្នាបានអះអាងថា ខ្លួនបានសម្រេចចិត្តមកជួយ កម្ពុជាដោយសារតែប្រវត្តិសាស្ត្ររបស់កម្ពុជាក្រោយរបបខ្មែរក្រហម ស្រដៀងគ្នានឹងប្រវត្តិសាស្ត្ររបស់ជប៉ុនក្រោយសង្គ្រាមលោកលើកទីពីរ ពោលគឺប្រទេសបានខ្ទេចខ្ទី រីឯប្រជាជនក៏បានស្លាប់អស់ជាច្រើន។

កម្ពុជានិងជប៉ុនមានទំនាក់ទំនងបួនដំណាក់កាល **ដំណាក់កាលទីមួយ** គឺទំនាក់ទំនងទ្វេភាគីដែលមានមូលដ្ឋាននៅលើជំនួយនិងប្រាក់កម្ចីច្រើនរយលានដុល្លាររបស់ ជប៉ុនដល់កម្ពុជាក្នុងមួយឆ្នាំៗ ព្រមទាំងការពង្រឹងសហប្រតិបត្តិការផ្សេងៗ ដូចយ៉ាងនៅលើវិស័យវប្បធម៌ អប់រំជាតិ ទេសចរណ៍ និងសុខាភិបាល។ **ដំណាក់កាលពីរ** គឺទំនាក់ទំនង នៅក្នុងក្របខ័ណ្ឌនៃជំនួបកំពូលរវាងជប៉ុន និងបណ្តាប្រទេសតាមដង ទន្លេមេគង្គ រួមមានមីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។ គឺនៅក្នុងទំនាក់ទំនងគន្លាក់ទីពីរនេះហើយ ដែលជប៉ុនបាននឹងកំពុងបន្តផ្តល់ប្រាក់រាប់រយលានដុល្លារ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់គ្នារវាងបណ្តាប្រទេសតាមដងទន្លេមេគង្គទាំងនេះ។ **ដំណាក់កាលទីបី** នៃទំនាក់ទំនងរវាងកម្ពុជានិងជប៉ុន វាប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌជំនួបកំពូលរវាងអាស៊ាន និងជប៉ុន។ **ដំណាក់កាលទីបួន** គឺនៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរវាងអង្គការសហប្រជាជាតិ និង កម្ពុជា។ គឺនៅក្នុងគន្លាក់ទីបួននេះហើយដែលគេ ត្រូវដឹងថា បើកុំតែបានជំនួយមុនគេបង្អស់របស់ជប៉ុនកាលពីប៉ុន្មានឆ្នាំមុននេះ ម្ល៉េះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមិនអាចកើតចេញជារូបរាងបានឡើយ។

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៣ សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងនាយករដ្ឋមន្ត្រី ប្រទេសជប៉ុន មានកិច្ចប្រជុំកំពូលមួយ និងបានព្រមព្រៀងបង្កើត«ភាពជាដៃគូថ្មី» ដើម្បីការពង្រីកទំនាក់ទំនងទ្វេភាគី ជប៉ុន-កម្ពុជា។ ហើយកិច្ចព្រមព្រៀងនេះបានធ្វើឡើងក្នុងឱកាសដែល

---

[11] *Chheang Vannarith, Cambodia Between China and Japan, 2009, p06,pdf*

នាយករដ្ឋមន្ត្រី ជប៉ុន ឯកឧត្តមស៊ិនហ្សូអាបេ បានបំពេញទស្សនកិច្ច២ថ្ងៃនៅកម្ពុជា។ កិច្ចព្រមព្រៀងបង្កើតភាពជាដៃគូថ្មី មានការចុះហត្ថលេខា ដោយនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ។

វិស័យសំរាប់កិច្ចសហប្រតិបត្តិការដែលបានជជែកនិងព្រមព្រៀង ក្នុងកិច្ចប្រជុំកំពូលរវាងសម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ស៊ិនហ្សូ អាបេ រួមមានទាំងអស់៥ចំណុចៈ

ទី១ បានផ្តោតលើបញ្ហានយោបាយនិងសន្តិសុខ

ទី២ បានផ្តោតលើលទ្ធិប្រជាធិបតេយ្យនិងនិតិរដ្ឋ

ទី៣ ទំនាក់ទំនង សេដ្ឋកិច្ចនិងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ទី៤ ការផ្លាស់ប្តូរប្រជាជននិងប្រជាជននិងវិស័យវប្បធម៌

ទី៥ កិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាក្នុងតំបន់ និងលើសាកលលោក។

នៅ៨ ខែមេសា ឆ្នាំ២០១៨ លោក តារ៉ូ កូណូ (Taro KONO) រដ្ឋមន្ត្រីការបរទេសជប៉ុនបានមកបំពេញទស្សនកិច្ចផ្លូវការជាលើកទី១នៅកម្ពុជា លោកថា មានអាទិភាពសំខាន់ចំនួនបីដែលរដ្ឋាភិបាលជប៉ុនបន្តជួយដល់កម្ពុជារួមមាន ទី១ គឺប្រព័ន្ធ logistic ទី២គឺការបណ្តុះបណ្តាលធនធានមនុស្ស និងទី៣គឺការពង្រឹងមុខងារសេវាទីក្រុង។[12]

ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែនបានអនុញ្ញាតឱ្យឯកឧត្តម yamamoto KOZO សមាជិកសភាជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ហើយនៅក្នុងដំណើរទស្សនកិច្ច មកកាន់កម្ពុជា នាពេលនេះ គឺមានគោលដៅពីរ ទី១ គឺដើម្បីសិក្សាអំពីសេវាទូទាត់ប្រាក់តាមប្រព័ន្ធទូរស័ព្ទ និងការអភិវឌ្ឍអ្វីដែលហៅថា Blockchain។ ឯកឧត្តមបានមានប្រសាសន៍ថា ការអភិវឌ្ឍ Blockchain នេះប្រសិនណាបើកម្ពុជាបានដាក់ចេញនិងប្រើប្រាស់ហើយនោះ កម្ពុជាគឺជាប្រទេសទីមួយហើយ ដែលបានដាក់ចេញនូវប្រព័ន្ធប្រើប្រាស់ឌីជីថលដ៏ទំនើបនេះ។ ទី២ គឺឯកឧត្តមមានបំណងធ្វើការសិក្សាអំពីបញ្ហាផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុងភ្នំពេញ។[13]

## ២.៣.ទំនាក់ទំនងផ្នែកសេដ្ឋកិច្ច

ចាប់តាំងពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១២ ប្រទេសជប៉ុនបានផ្តល់ជំនួយឥតសំណងមានទឹកប្រាក់ចំនួន ៦៣៣ ,៣៥៩ លានដុល្លារអាម៉េរិក ផ្តល់កម្ចីសម្បទានចំនួន ៣៨០,៥៧ លានដុល្លារ ផ្តល់ជំនួយបច្ចេកទេសពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១២ មានទឹកប្រាក់ចំនួន ២៨០,៨៤៤ លានដុល្លារអាម៉េរិកនិងផ្តល់ជំនួយដល់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាពីឆ្នាំ ២០០៥ ដល់ខែកុម្ភៈ ឆ្នាំ២០១២ មានទឹកប្រាក់ចំនួន ៧៦.៦៤ លានដុល្លារអាម៉េរិក។ ជាមួយគ្នានេះប្រទេសជប៉ុនបានជួយ បណ្តុះបណ្តាលធនធានមនុស្សចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១២ ក្នុងនោះសំរាប់វគ្គសិក្សារយៈពេលខ្លី

---

*[12] កម្ពុជាថ្មី ៖ ចុះផ្សាយថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៨ ៖ "រដ្ឋមន្ត្រីការបរទេសជប៉ុន បញ្ជាក់ពីអាទិភាពសំខាន់ចំនួន៣ ដែលរដ្ឋាភិបាលជប៉ុនបន្តជួយដល់កម្ពុជា"។*

*[13] ទីស្តីការគណៈរដ្ឋមន្ត្រី ៖ ចុះផ្សាយថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ៖ "សម្តេចតេជោ ហ៊ុន សែន លើកទឹកចិត្តឱ្យជប៉ុនធ្វើការសិក្សានិងពន្លឿនការប្រើប្រាស់សេវាកម្ម ទូទាត់ប្រាក់តាមប្រព័ន្ធឌីជីថល ឱ្យបានល្អប្រសើរ"។*

មានចំនួន ៨៧៨ នាក់ និងវគ្គសិក្សារយៈពេលវែងមាន ៥៤៣ នាក់។ ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០១២ អ្នកស្ម័គ្រចិត្តជប៉ុនមកកាន់កម្ពុជាមានចំនួន ១៧៧ នាក់ ផ្តល់អ្នកជំនាញការពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០១២ មានចំនួន ២៧៩១ នាក់រួមទាំងការផ្តល់នូវសម្ភារៈសង្គ្រោះបន្ទាន់មានទឹកប្រាក់ចំនួន ៣៣០ ពាន់ដុល្លាអាម៉េរិកកាលពីខែតុលាឆ្នាំ២០១១[14]។

ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៨ សម្តេចតេជោ ហ៊ុន សែន បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាវវាង ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេស និង លោក Taro Kono ស្តីពីការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលជប៉ុនមកកាន់រាជរដ្ឋាភិបាលកម្ពុជាមាន៖

១- ហិរញ្ញប្បទានឥតសំណងជប៉ុន ដែលមានទឹកប្រាក់សរុបចំនួន ៥០០ លានយ៉េន (¥ ៥០០,០០០,០០០) សម្រាប់អនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នៅកម្ពុជា

២- ឥណទានសម្បទានជប៉ុន ដែលមានទឹកប្រាក់សរុបចំនួន ៩.២១៦ លានយ៉េន (¥ ៩,២១៦,០០០,០០០) សម្រាប់អនុវត្តគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយអគ្គិសនី នៅរាជធានីភ្នំពេញ ជំហានទី២។[15]

ក្នុងក្របខណ្ឌនៃការវិនិយោគផ្ទាល់ពីជប៉ុន ដោយគិតចាប់តាំងពីឆ្នាំ១៩៩៤ រហូតដល់ត្រីមាសទី១ឆ្នាំ២០១៩ គម្រោងវិនិយោគរបស់ក្រុមហ៊ុនជប៉ុន មានចំនួន១៣៧គម្រោង ក្នុងនោះមានទុនវិនិយោគសរុបចំនួន ២,៥៣ន់លានដុល្លារ។ ក្រុមហ៊ុនជប៉ុនទាំងនេះ ភាគច្រើនផ្តោតទៅលើការផលិតគ្រឿងបង្គុំអគ្គិសនីនិងអេឡិចត្រូនិក គ្រឿងបង្គុំរថយន្ត និងសម្ភារៈបរិក្ខាបច្ចេកទេស កសិ-ឧស្សាហកម្ម ការកែច្នៃម្ហូបអាហារ សណ្ឋាគារ ទេសចរណ៍ មន្ទីរពេទ្យ និងផ្សារទំនើប។[16]

## ២.៤.កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន

**កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន** ត្រូវបានបង្កើតឡើងនៅចាប់តាំងពីឆ្នាំ២០០៨ ដែលមាន ប្រទេសជាសមាជិកចំនួន៦គឺ កម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ វៀតណាម និងជប៉ុន។ នៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុនលើកទី១០ ដែលប្រារព្ធធ្វើឡើងនៅទីក្រុងតូក្យូ ប្រទេសជប៉ុន នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៨ ក្នុងកិច្ចប្រជុំកំពូលនេះ មេដឹកនាំប្រទេសតំបន់ទន្លេមេគង្គទាំង៥ និងជប៉ុន បានសម្រេចដាក់ចេញនូវ «យុទ្ធសាស្ត្រទីក្រុងតូក្យូឆ្នាំ២០១៨ សម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន» សម្មៅពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការប្រទេសតំបន់មេគង្គ និងជប៉ុន ក៏ដូចជាឆ្លើយតបបញ្ហានៅក្នុងតំបន់ និងលើពិភពលោកនាពេលបច្ចុប្បន្ន។ «យុទ្ធសាស្ត្រទីក្រុងតូក្យូឆ្នាំ២០១៨

[14] *អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ៖ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ៖ រដ្ឋទាយាទរាជាណាចក្រជប៉ុនវាយតម្លៃខ្ពស់ចំពោះ តួនាទីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងការពង្រឹងសន្តិភាពនិងស្ថិរភាពនៅកម្ពុជា។*

[15] *នគរវត្តហ្គូន nkdnews ៖ ចុះផ្សាយថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៨ ៖ "សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីការបរទេសជប៉ុន"។*

[16] *វិទ្យុបារាំង ៖ ចុះផ្សាយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ៖ "ជប៉ុនផ្តល់ជំនួយឥតសំណងប្រហែល៥លានដុល្លារសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងធនធានមនុស្សរបស់កម្ពុជា"។*

សម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន» បានដាក់ចេញ នូវយុទ្ធសាស្ត្រចម្បងៗចំនួន៣រួមមាន៖ ១. សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ន នៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន, ២. សសរស្តម្ភថ្មីបីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងទី៣. បញ្ហាតំបន់ និងសកល។

**សមិទ្ធផល និងស្ថានភាពបច្ចុប្បន្ននៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន៖** មេដឹកនាំប្រទេសមេគង្គ និងជប៉ុន បានលើកសរសើរពីសមិទ្ធផលនៃ «យុទ្ធសាស្ត្រទីក្រុងតូក្យូថ្មីឆ្នាំ២០១៥» និងការអនុវត្តជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ក្នុងទំហំទឹកប្រាក់ជាង ៧៥០ពាន់លានយ៉េន ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ហើយក្នុងឱកាសប្រារព្ធខួបលើកទី១០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុននេះ មេដឹកនាំនៃប្រទេសមេគង្គ និងជប៉ុន បានសម្រេចពង្រីកទំនាក់ទំនងរវាងប្រទេសជប៉ុន និងប្រទេសគង្គទៅជាដៃគូយុទ្ធសាស្ត្រ។ មេដឹកនាំមេគង្គ-ជប៉ុន ក៏បានសម្រេចដាក់ចេញកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងទិសដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs), កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលសេរី និងបើកចំហរ និងកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (Ayeyawady-Chao Phraya-Mekong Economic Cooperation Strategy-AMECS)។

**កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងទិសដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)៖** បានសម្រេចប្តូរផែនការសកម្មភាព «ទសវត្សឆ្ពោះទៅរកតំបន់មេគង្គបៃតង» ត្រឹមឆ្នាំ២០២០ ទៅជា «គំនិតផ្តួចផ្តើមមេគង្គ-ជប៉ុនសម្រាប់ទិសដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្ពោះទៅរកឆ្នាំ២០៣០»។ កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលសេរី និងបើកចំហរ៖ ថ្នាក់ដឹកនាំទាំងអស់ បានបញ្ជាក់ពីសារៈសំខាន់នៃការកិច្ចខិតខំប្រឹងប្រែង ជាបន្តបន្ទាប់របស់ប្រទេសមេគង្គនីមួយៗក្នុងការពង្រឹងសណ្តាប់ធ្នាប់ដែលសេរី និងបើកចំហរដោយឈរលើគោលការណ៍ នីតិរដ្ឋ ដើម្បីធានាឲ្យមានសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ និងបានបញ្ជាក់ថា តំបន់មេគង្គ ដែលតភ្ជាប់ពីមហាសមុទ្រឥណ្ឌា ទៅមហាសមុទ្រប៉ាស៊ីហ្វិក មានអំណោយផលផ្នែកភូមិសាស្ត្រ ដែលអាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការសម្រេចបាននូវតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលសេរី និងបើកចំហរ។ ក្នុងន័យនេះថ្នាក់ដឹកនាំនៃបណ្តាប្រទេសមេគង្គទាំងអស់ បានស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ជប៉ុនក្រោម «យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិកដែលសេរី និងបើកចំហរ» ព្រមទាំងបានសម្តែងនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការមេគង្គ-ជប៉ុន ដែលរួមចំណែកដល់យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលសេរី និងបើកចំហរ។

**កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និងយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ៖** ជប៉ុន បានវាយតម្លៃខ្ពស់ចំពោះ ACMECS ថា ជាគំនិតផ្តួចផ្តើមផ្ទាល់មួយរបស់ប្រទេសទន្លេមេគង្គ ហើយយល់ថា គួរស្វែងរកសហថាមពលរវាងកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន និង ACMECS។ មេដឹកនាំមេគង្គ បានស្វាគមន៍គោលបំណងជប៉ុន ក្នុងការចូលរួមក្នុងកិច្ចប្រជុំដែលពាក់ពូន្ធនឹង ACMECS។

**កិច្ចប្រជុំកំពូលមេដឹកនាំមេគង្គ-ជប៉ុនលើកទី១០ មេដឹកនាំប្រទេសមេគង្គ និងជប៉ុន ក៏បានដាក់ចេញសសរស្តម្ភកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន ចំនួន ៣រួមមាន៖** ១. ការតភ្ជាប់រស់រវើក និងមានប្រសិទ្ធិភាព ផ្តោតលើការងារ (តភ្ជាប់ផ្នែករឹង, តភ្ជាប់ផ្នែកទន់, តភ្ជាប់ផ្នែកឧស្សាហកម្ម), ២. សង្គមដែលផ្តោតលើមនុស្សជាចម្បង ដោយផ្តោលើការងារ (ការអភិវឌ្ឍធនធានមនុស្ស, ការថែទាំងសុខមាលភាព, ការអប់រំ, កិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់ និងតុលាការ) និងទី៣. ការសម្រេចបាននូវមេគង្គបៃតង ដោយផ្តោតលើការងារ (កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ, គ្រប់គ្រងធនធានទឹក, ការគ្រប់គ្រងកាកសំណល់, ការអភិរក្ស និងការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព រួមទាំងថនិកសត្វក្នុងសមុទ្រ)។

**បញ្ហាតំបន់ និងសកល ៖** ប្រមុខរដ្ឋ/រដ្ឋាភិបាលមេគង្គ-ជប៉ុន បានបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញាចិត្ត ដ៏រឹងមាំរបស់ខ្លួនក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជិតស្និទ្ធ លើបញ្ហាតំបន់ និងសកលនានា ដែលជាការព្រួយបារម្ភ ដើម្បីធានាសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ និងសកលលោក។ ប្រមុខដឹកនាំបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ ក៏ដូចជាដោះស្រាយជម្លោះដោយសន្តិវិធី រួមទាំងការគោរពពេញលេញចំពោះនីតិវិធីច្បាប់ និងការទូត ដោយមិនជ្រើសយកការគំរាមកំហែង ឬការប្រើប្រាស់កម្លាំងដោយអនុលោមតាមគោលការច្បាប់អន្តរជាតិ ដែលមានការទទួលស្គាល់ជាសកល។[17]

តាមការផ្សាយរបស់ក្រសួងការបរទេសស្តីពីលទ្ធផលនៃកិច្ចប្រជុំកិច្ចសហប្រតិបត្តិការមេគង្គថ្ងៃទី១-៣ ខែសីហា ឆ្នាំ២០១៩ នៅប្រទេសថៃ បានបញ្ជាក់ខ្លឹមសារដូចខាងក្រោម៖

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១២ ថា កិច្ចប្រជុំបានសម្រេចដាក់គំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន សម្រាប់ទិសដៅអភិវឌ្ឍប្រកដោយចីរភាពឆ្នាំ២០៣០ ឲ្យអនុម័តនៅកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុនដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៩ នៅប្រទេសថៃ។ វិស័យអាទិភាពស្ថិតក្រោមគំនិតផ្តួចផ្តើមនេះ នឹងគ្របដណ្តប់លើបញ្ហាបរិស្ថាន និងបញ្ហារបស់ទីក្រុង កសិកម្ម និងបរិយាប័ន្ន។ កិច្ចប្រជុំបានអបអរសាទរការឯកភាពលើព្រឹត្តិការណ៍ចំនួនជាង១០០ សម្រាប់ធ្វើជាព្រឹត្តិការណ៍ដើម្បីអបអរសសាទរ "ឆ្នាំផ្លាស់ប្តូមេគង្គ-ជប៉ុន២០១៩"។ រដ្ឋមន្ត្រីមេគង្គ-ជប៉ុនបានឯកភាពរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១៣ នៅឆ្នាំ២០២០ នៅប្រទេសជប៉ុន។ កិច្ចប្រជុំក៏បានអនុម័តសេចក្តីប្រកាសសហប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១២។[18]

---

*[17] Apsaracentral ៖ ចុះផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៨ ៖ "កិច្ចប្រជុំកំពូលមេគង្គ-ជប៉ុនលើកទី១០ ដែលធ្វើឡើងនៅទីក្រុងតូក្យូ ប្រទេសជប៉ុន"។*

*[18] ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ចុះផ្សាយថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ ៖ "សេចក្តីប្រកាសព័ត៌មាន៖ លទ្ធផលនៃកិច្ចប្រជុំកិច្ចសហប្រតិបត្តិការមេគង្គ នាថ្ងៃទី ១-៣ ខែសីហា ឆ្នាំ២០១៩ នៅទីក្រុងបាងកក"។*